ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សភាព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១៨៧

ចុះថ្ងៃទី២១ ខែសីហា ឆ្នាំ២០១៩

សាលដីកា

លេខ ៥០ "VI"

ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០២០

# សាលដីកា

## តាងនាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២០

ដោយមានសមាសភាពអង្គជំនុំជម្រះដូចខាងក្រោម ៖

១-ឯកឧត្តម [redacted] ជាប្រធាន

២-លោក [redacted] ជាចៅក្រម

៣-លោក [redacted] ជាចៅក្រម

៤-លោក [redacted] ជាចៅក្រម

៥-លោកស្រី [redacted] ជាចៅក្រមរបាយការណ៍

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted]

**តំណាងមហាអយ្យការ**

លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

**ដើម្បីជំនុំជម្រះ**

លើបណ្តឹងសាទុក្ខលេខ ៤៦៦ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] កាណាល់ ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ៦៤ ក្រVI "ច" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់សភាព្រហ្មទណ្ឌសាលាឧទ្ធរណ៍ភ្នំពេញដែលមាន៖

**បុគ្គលប្តឹងសាទុក្ខ ៖** ជនជាប់ចោទឈ្មោះ [redacted] **កាណាល់** ភេទប្រុស ឆ្នាំកំណើត១៩៩១ ជនជាតិខ្មែរ មានទីកន្លែងកំណើត៖ [redacted] មុខរបរលក់នំ ប្រពន្ធឈ្មោះ [redacted] ។ ទោសពីមុនគ្មាន។

លោកស្រីមេធាវី [redacted] សុវ៉ន ជាអ្នកការពារ ។

Scanned with CamScanner

**ដាច់ទោសពីបទ៖** ជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅចំណុច ក្រុម៤ ភូមិ ៣ សង្កាត់លេខ ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌមានចែងឱ្យផ្តន្ទាទោសតាមបទប្បញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៦ ចំណុច ទី៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ វេលាម៉ោង ២០ និង ១៥ នាទី នៅក្រុមទី៤ ភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កម្លាំងជំនាញការិយាល័យប្រឆាំងគ្រឿងញៀននៃស្នងការដ្ឋាននគរបាលខេត្តព្រះសីហនុ បានបង្ក្រាបករណីជួញដូរដោយខុសច្បាប់នូវសារធាតុញៀនមួយករណី ហើយឃាត់ខ្លួនជនសង្ស័យចំនួន ២ នាក់ មានឈ្មោះ [redacted] កាណាល់ ភេទប្រុស និងឈ្មោះ [redacted] ខេមរ័ត្ន ភេទប្រុស ខណៈពេលដែលពួកគេកំពុងធ្វើសកម្មភាពជួញដូរនៅក្នុងបន្ទប់ជួល ព្រមជាមួយនឹងថ្នាំមានផ្ទុកសារធាតុញៀនចំនួន ០១ កញ្ចប់ ទម្ងន់សុទ្ធ ៩៧ , ៩០ ក្រាម និងឧបករណ៍ជក់មួយចំនួន ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ៤៤ "គ" ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តព្រះសីហនុ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសលើឈ្មោះ [redacted] កាណាល់ ភេទប្រុស កើតឆ្នាំ១៩៩១ ជនជាតិខ្មែរ សញ្ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ១០ (ដប់) ឆ្នាំ ។

២-ផ្តន្ទាទោសលើឈ្មោះ [redacted] ខេមរ័ត្ន ភេទប្រុស កើតឆ្នាំ១៩៨៧ ជនជាតិខ្មែរ សញ្ជាតិខ្មែរ (មានសាវតាជាតិដូចខាងលើ) ដាក់ពន្ធនាគារកំណត់ ១០ (ដប់) ឆ្នាំ ។

ពីបទជួញដូរនិងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តទៅក្រុម៤ ភូមិ៣ សង្កាត់លេខ២ ក្រុងព្រះសីហនុ ខេត្តព្រះសីហនុ កាលពីថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៦ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមបទប្បញ្ញត្តិមាត្រា ៤០ កថាខណ្ឌទី៦ ចំណុចទី៤ និងមាត្រា ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

៣-វត្ថុតាងដែលដកហូតបានមាន ៖

ក.ម្សៅសថ្លាមួយថង់ មានទម្ងន់ ៩៧,៩០ ក្រាម (បរិមាណភាពសុទ្ធមាន ៨២,៤៩% នៃទម្ងន់សរុប) ដបជក់ចំនួនមួយ និងដែកកេះចំនួនបី សម្រេចរឹបអូសនឹងបំផ្លាញចោល ។

ខ.ទូរស័ព្ទចំនួនពីរគ្រឿង , លុយខ្មែរចំនួន ៥០.០០០(ប្រាំម៉ឺន) រៀល សម្រេចរឹបអូសទុកជាសម្បត្តិរដ្ឋ ។

Scanned with CamScanner

សាលក្រមនេះបានជំនុំជម្រះនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០១៧ និងប្រកាសជាសាធារណៈ នៅថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] កាណាល់ , [redacted] ខេមរ័ត្ន និងមេធាវីការពារឲ្យជនជាប់ចោទ។ ទុកសិទ្ធិប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ១០៧ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] កាណាល់ ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៤ "គ" ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តព្រះសីហនុ ត្រង់ចំណុចផ្ដន្ទាទោសខ្លួនដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ នៃសេចក្ដីសម្រេចបញ្ចប់នៃសាលក្រម។

-បានឃើញ បណ្ដឹងឧទ្ធរណ៍លេខ ១០៦ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ខេមរ័ត្ន ដែលប្ដឹងមិនសុខចិត្តនឹងសាលក្រមព្រហ្មទណ្ឌលេខ ៤៤ "គ" ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ ២០១៧ របស់សាលាដំបូងខេត្តព្រះសីហនុ ត្រង់ចំណុចផ្ដន្ទាទោសខ្លួនដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ នៃសេចក្ដីសម្រេចបញ្ចប់នៃសាលក្រម។

-បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ៦៤ "ក្រ.VI.ច" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលមានខ្លឹមសារនៃសេចក្ដីសម្រេចដូចតទៅ៖

១-ក ទទួលបណ្ដឹងឧទ្ធរណ៍លេខ ១០៦ ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ខេមរ័ត្ន ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាស់។

ខ-ទទួលបណ្ដឹងឧទ្ធរណ៍លេខ ១០៧ ចុះថ្ងៃទី០៨ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] កាណាល់ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយទាស់នឹងគតិច្បាប់ ។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៤ (គ) ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ២០១៧ របស់សាលាដំបូងខេត្តព្រះសីហនុ ទុកជាបានការដដែល។

៣-បន្តឃុំខ្លួនជនជាប់ចោទតាមច្បាប់ ។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១៨ និងប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ ចំពោះមុខជនជាប់ចោទ, មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ ។ បើកសិទ្ធិផ្ដល់ប្ដឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

-បានឃើញ បណ្ដឹងសាទុក្ខលេខ ៤៦៦ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] កាណាល់ បានប្ដឹងមិនសុខចិត្តនិងសាលដីកាព្រហ្មទណ្ឌលេខ ៦៤ "ក្រ.VI.ច" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ត្រង់ចំណុចទាំងមូលនៃសេចក្ដីសម្រេច។

**នាពេលសវនាការ**

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

Scanned with CamScanner

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋាននិងប្តឹងសុំថា ជនជាប់ចោទឈ្មោះ [redacted] កាណាល់ បានទទួលស្គាល់នូវអំពើរបស់ខ្លួនដែលបានប្រព្រឹត្តនៅចំពោះមុខតុលាការអង្គសេចក្តីហើយ។ ដូច្នេះ ការចោទប្រកាន់ និងសម្រេចរបស់តុលាការមានលក្ខណៈត្រឹមត្រូវហើយ។

តំណាងមហាអយ្យការស្នើសុំក្រុមប្រឹក្សាជំនុំជម្រះសម្រេច

ទទួលបណ្តឹងសាទុក្ខលេខ ៤៦៦ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted]កាណាល់ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធដោយខុសទៅនឹងគតិច្បាប់។

តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៦៤ “ក្រ.IV.ច” ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

-ជនជាប់ចោទឈ្មោះ [redacted] កាណាល់ បានឆ្លើយថា ខ្លួនពិតជាបានប្រព្រឹត្តអំពើជួញដូរនិងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន។

-លោកស្រីមេធាវី [redacted] សុវ៉ន ការពារក្តីឱ្យជនជាប់ចោទឈ្មោះ [redacted]កាណាល់ ធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនពិតជាបានប្រព្រឹត្តអំពើជួញដូរនិងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប៉ុន្តែការប្រព្រឹត្តនេះគឺមកពីកូនក្តីខ្លួនមានជីវភាពក្រលំបាក ត្រូវចិញ្ចឹមគ្រួសារនិងម្តាយចាស់ជរា និងមិនដឹងថាជាអំពើមួយដែលល្មើសនឹងច្បាប់ និងត្រូវទទួលរងនូវទណ្ឌកម្មធ្ងន់ធ្ងរ និងបានសហការជាមួយកងកម្លាំងមានសមត្ថកិច្ចយ៉ាងល្អ។ ក្នុងអំឡុងពេលនៅពន្ធនាគារកូនក្តីខ្លួនបានកែប្រែអត្តចរិតបានល្អ មិនដែលប្រព្រឹត្តអ្វីខុសទៅនិងបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ និងបានកែខ្លួនជាពលរដ្ឋល្អ។

<u>សំណូមពរ៖</u> សុំឱ្យតុលាការកំពូលមេត្តាបន្ធូរបន្ថយទណ្ឌកម្មឱ្យកូនក្តីខ្លួន ដើម្បីឱ្យកូនក្តីខ្លួនឆាប់បានចេញទៅរួមរស់ក្នុងសង្គមជាតិវិញ និងបានមើលថែប្រពន្ធ និងកូនតូចៗនៅក្នុងបន្ទុក។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted]កាណាល់ និងសេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យ ពិចារណា ពិភាក្សា វិនិច្ឆ័យ ត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

## តុលាការកំពូល

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ៤៦៦ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] កាណាល់ ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបាន តាមបទប្បញ្ញត្តិមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងបទប្បញ្ញត្តិមាត្រា ៤១៧ , មាត្រា ៤១៨ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

Scanned with CamScanner

២-យល់ឃើញថា នាពេលសវនការនៅតុលាការកំពូល ជនជាប់ចោទឈ្មោះ [redacted] កាណាល់ បានឆ្លើយទទួលស្គាល់ថា ខ្លួនពិតជាបានប្រព្រឹត្តអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដូចការចោទប្រកាន់មែន ហើយនិងមេធាវីការពារក្តីឱ្យជនជាប់ចោទក៏បានធ្វើសេចក្តីសន្និដ្ឋានដោយទទួលស្គាល់ថា កូនក្តីរបស់ខ្លួនពិតជាបានប្រព្រឹត្តអំពើជួញដូរ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ដូចការចោទប្រកាន់មែន។ ក៏ប៉ុន្តែការប្រព្រឹត្តនេះគឺមកពីកូនក្តីខ្លួនមានជីវភាពក្រលំបាក និងមិនដឹងថាជាអំពើមួយដែលល្មើសនឹងច្បាប់ និងត្រូវទទួលរងនូវទណ្ឌកម្មធ្ងន់ធ្ងរដូច្នេះនោះទេ។ ប៉ុន្តែនៅពេលដែលសមត្ថកិច្ចចាប់កូនក្តីខ្លួនបាន កូនក្តីខ្លួនបានឆ្លើយទទួលស្គាល់នូវកំហុសរបស់ខ្លួន និងបានសហការជាមួយកងកម្លាំងមានសមត្ថកិច្ចយ៉ាងល្អ។ ម៉្យាងវិញទៀត ក្នុងអំឡុងពេលរស់នៅក្នុងពន្ធនាគារកន្លងមក កូនក្តីខ្លួនបានកែប្រែអត្តចរិតបានល្អ មិនដែលប្រព្រឹត្តអ្វីខុសទៅនឹងបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារនោះទេ និងបានកែខ្លួនជាពលរដ្ឋល្អឡើងវិញហើយ ។ ហេតុដូច្នេះ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] កាណាល់ សូមសំណូមពរដល់តុលាការសុំឱ្យតុលាការកំពូលមេត្តាបន្ធូរបន្ថយទណ្ឌកម្មឱ្យកូនក្តីខ្លួន ដើម្បីអាចឱ្យកូនក្តីខ្លួនឆាប់បានទៅរួមរស់នៅក្នុងសង្គមជាតិវិញ និងបានមើលថែប្រពន្ធ និងកូនតូចៗ នៅក្នុងបន្ទុក គឺជាចម្លើយ និងសេចក្តីសន្និដ្ឋានពុំមានបង្ហាញអំពីមូលហេតុនៃបណ្តឹងសាទុក្ខនោះទេ ។ ហើយវាក៏មិនមែនជាស្ថានសម្រាលតាមផ្លូវច្បាប់នោះដែរ ។ ម៉្យាងវិញទៀត តុលាការអង្គហេតុទាំង ២ ថ្នាក់ ក៏បានផ្តន្ទាទោសជនជាប់ចោទឈ្មោះ ខៀវ កាណាល់ ក្នុងកម្រិតអប្បបរមារួចហើយដែរ ។

៣-យល់ឃើញថា សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលបានលើកឡើងអះអាងថា បណ្តឹងសាទុក្ខរបស់ជនជាប់ចោទឈ្មោះ [redacted] កាណាល់ គ្មានមូលហេតុបណ្តឹងសាទុក្ខតាមបទប្បញ្ញត្តិច្បាប់ទេ ហេតុដូចនេះ សុំឱ្យតុលាការកំពូលពិចារណាទៅតាមទិដ្ឋភាពច្បាប់ ។ សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការអមតុលាការកំពូលដូចនេះ មានខ្លឹមសារដូចការដែលតុលាការកំពូលបានលើកយកមកពិនិត្យ ពិចារណា វិនិច្ឆ័យ ដូចមានក្នុងសំអាងហេតុត្រង់ចំណុចទី២ ខាងលើនេះរួចហើយ។

តុលាការកំពូលក៏កត់សម្គាល់ឃើញផងដែរថា តុលាការអង្គហេតុមិនបានអនុវត្តច្បាប់ស្តីពីការត្រួតពិនិត្យ គ្រឿងញៀនដែលជាច្បាប់សារធាតុឱ្យបានត្រឹមត្រូវតាមខ្លឹមសារនៃបទប្បញ្ញត្តិមាត្រា២៧ និងមាត្រា ២៨ នៃច្បាប់ ស្តីពីការត្រួតពិនិត្យគ្រឿងញៀន និងបទប្បញ្ញត្តិមាត្រា ៦៦៨ នៃក្រមព្រហ្មទណ្ឌនោះឡើយ ។ ពីព្រោះច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿង គឺជាបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌមានចរិតពិសេស ។ ការអនុវត្តបទប្បញ្ញត្តិច្បាប់ព្រហ្មទណ្ឌមានចរិតពិសេស តុលាការមិនត្រូវអនុវត្តដោយយោងតាមខ្លឹមសារនៃបទប្បញ្ញត្តិត្រង់កថាខណ្ឌទី២ នៃមាត្រា ៦៦៨ និងមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌនោះទេ ។ ដោយក្នុងរឿងក្តីនេះ តុលាការអង្គហេតុមិនបានអនុវត្តការផ្តន្ទាទោសពិន័យជាប្រាក់លើជនជាប់ចោទ នេះគឺជា

Scanned with CamScanner

កំហុស។ ក៏ប៉ុន្តែ ដោយហេតុថា តុលាការកំពូលនាពេលនេះ សម្រេចតែទៅលើ បណ្តឹងសាទុក្ខរបស់ជនជាប់ចោទ ដូច្នេះតុលាការកំពូលមិនអាចសម្រេចបន្ថែមទម្ងន់ទោសទៅលើជនជាប់ចោទបានទេ ។

៤-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ៦៤ "ក្រ.VI.ច" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ដែលបានសម្រេចសេចក្តីមកនេះត្រឹមត្រូវតាមគតិច្បាប់ហើយ។

## ហេតុដូច្នេះ

## សម្រេចសេចក្តី

១-បដិសេធបណ្តឹងសាទុក្ខលេខ ៤៦៦ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ របស់ជនជាប់ចោទឈ្មោះ [redacted] កាណាល់ ដោយមូលហេតុខុសនឹងគតិច្បាប់ ។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ៦៤ "ក្រ.VI.ច" ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៨ របស់សាលាឧទ្ធរណ៍ភ្នំពេញ ទុកជាបានការដដែល ។

សាលដីកានេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃសុក្រ ទី១៤ ខែកុម្ភៈ ឆ្នាំ២០២០ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃសុក្រ ទី២៨ ខែកុម្ភៈ ឆ្នាំ២០២០ ។

Scanned with CamScanner